អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក នឹងជួយគាំទ្រដល់វិស័យនាំចេញ និងវិនិយោគកម្ពុជា
- វិស័យធនាគារកម្ពុជា នៅតែមានសុខភាពល្អ និងមានភាពធន់ នៅឆមាសទី១ ឆ្នាំ២០២១
- ធនាគារពិភពលោក បានប្ដេជ្ញាជួយជំរុញសេដ្ឋកិច្ចកម្ពុជាទោះបីនៅក្នុងអំឡុងការរីករាលដាលជំងឺកូវីដ១៩
- រាជរដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាចំនួន ៣៨០លានដុល្លារសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជំនួយសង្គម
- កសិករដំណាំបន្លែគ្រប់មុខខេត្តរតនគិរី រីករាយក្នុងការលក់បានតម្លៃខ្ពស់នៅឆ្នាំនេះ
- កសិករស្រុកឈូកខេត្តកំពត ដាំស្លឹកគ្រៃប្រេងសម្រាប់នាំចេញទៅកាន់ប្រទេសចិន និងបារាំង
- ក្រសួងហិរញ្ញវត្ថុវៀតណាមកំពុងធ្វើការលើកញ្ញប់ថវិកាជំនួយ ចំនួន ១,០៤ ប៊ីលានដុល្លារអាមេរិក
- ស្ថានភាពការអនុវត្តថវិកានៃប្រទេសកម្ពុជា ថៃ ហ្វីលីពីន និងវៀតណាម នៅ៥ខែដំបូង ឆ្នាំ២០២១
- វិស័យទេសចរណ៍ថៃឈានដល់កម្រិតទាបបំផុត នៅក្នុងឆ្នាំ២០២១
- ទីក្រុងភាគកណ្ដាល វៀតណាម ទាក់ទាញការវិនិយោគអំឡុងពេលនៃការវាយប្រហាយដោយកូវីដ១៩
- អាមេរិកដាក់គោលដៅជំរុញកំណើនសេដ្ឋកិច្ចសកល តាមបរិបទនៃការងើបឡើងវិញនៃសេដ្ឋកិច្ច
- អាស៊ាន មិនត្រូវបានគ្របដណ្ដប់ដោយគោលនយោបាយពន្ធសាជីវកម្មអប្បបរមាសកល ដែលអាចកាន់តែមានទំនាក់ទំនងជិតស្និទ្ធជាមួយចិន


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្ដាហ៍ទី៥ ខែកក្កដា ឆ្នាំ២០២១ លេខ ៖ ៧៨

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក នឹងជួយគាំទ្រដល់វិស័យនាំចេញ និងវិនិយោគកម្ពុជា




*ប្រភព៖ Khmer Times ២០២១, រូបភាព៖ ធនាគារជាតិនៃកម្ពុជា*

អគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ឯកឧត្តម ជា ចាន់តូ បានលើកឡើងថា ការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក នឹងអាចជួយគាំទ្រដល់វិស័យនាំចេញ និងវិនិយោគកម្ពុជា ដែលនឹងជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យមានកំណើនវិជ្ជមាន ក៏ដូចជា ជំរុញការងើបឡើងវិញនៃវិស័យទេសចរណ៍។

ទន្ទឹមនេះ ឯកឧត្តមបានគូសបញ្ជាក់ថា វិសមភាពក្នុងការទទួលបានវ៉ាក់សាំងនិងបញ្ហាក្នុងស្រុក បានធ្វើឱ្យការងើបឡើងនៃសេដ្ឋកិច្ចប្រទេសនីមួយៗ លើពិភពលោកមានភាពមិនស្មើគ្នា ដោយសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍នឹងងើបឡើងវិញលឿនជាងសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសមានទីផ្សារកំពុងងើបឡើង (Emerging and Developing Countries)។

ជាក់ស្តែង សេដ្ឋកិច្ចកម្ពុជា ក៏មិនខុសពីសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតដែរ ដែលនឹងអាចជួបប្រទះនឹងរលកថ្មីនៃជំងឺកូវីដ-១៩ ការកើនឡើងនៃបំណុលឯកជននិងសាធារណៈ និងការកើនឡើងនៃវិសមភាពនិងភាពក្រីក្រ។

ស្របពេលជាមួយគ្នានេះ ឯកឧត្តមក៏បានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវវិធានការ និងគោលនយោបាយ ដើម្បីទប់ស្កាត់និងកាត់បន្ថយការចម្លងរាលដាលនៃជំងឺកូវីដ-១៩ក្នុងសហគមន៍បានទាន់ពេលវេលា និងបានអនុវត្តនូវយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេសបានឆាប់រហ័ស។ ចំណែកឯ ធនាគារជាតិក៏បានអនុវត្តកញ្ចប់ជំរុញរូបិយវត្ថុ និងការសម្រួលលើវិធានការម៉ាក្រូ។ វិធានការនិងគោលនយោបាយទាំងនេះ បានជួយគាំទ្រដល់ជនក្រីក្រ និងគ្រួសារជនងាយរងគ្រោះ រួមទាំងវិស័យអាទិភាព ដែលបានទទួលរងការប៉ះទង្គិច។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Khmer Times ចេញផ្សាយ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១*

## ថ្វីបើមានវិបត្តិជំងឺរាតត្បាតកូវីដ-១៩ វិស័យធនាគារកម្ពុជា នៅតែមានសុខភាពល្អ និងមានភាពធន់ នៅឆមាសទី១ ឆ្នាំ២០២១



*ប្រភព៖ Khmer Times ២០២១*

យោងតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ដែលចេញផ្សាយនាពេលថ្មីៗនេះ បានបង្ហាញឱ្យឃើញពីភាពធន់ និងរឹងមាំនៃឧស្សាហកម្មធនាគារ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃប្រាក់បញ្ញើនិងកម្ចី នៅឆមាសទី១ ឆ្នាំ២០២១ ទោះបីស្ថិតក្នុងវិបត្តិជំងឺរាតត្បាតកូវីដ-១៩ក៏ដោយ។

របាយការណ៍នេះ បានបង្ហាញថា គិតត្រឹមខែមិថុនា ឆ្នាំ២០២១នេះ ប្រាក់កម្ចីសរុបមានចំនួន ៣៣,៩ប៊ីលានដុល្លារ ពោលគឺកើនឡើង ១៩% បើធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ រីឯ ប្រាក់បញ្ញើសរុប មានចំនួន ៣២,៧ប៊ីលានដុល្លារ ដែលមានកំណើន ២០,៨% ក្នុងកំឡុងពេលដូចគ្នា។ ជាក់ស្តែង កម្ចីត្រូវបានផ្តល់ទៅដល់វិស័យអាទិភាពដូចជា ពាណិជ្ជកម្ម គេហដ្ឋាន សំណង់ និងកម្មន្តសាល។

គួរបញ្ជាក់ថា ថ្វីបើកម្ចីនៅតែបង្ហាញពីកំណើន ក៏ប៉ុន្តែមិនមានសន្ទុះខ្លាំងដូចកាលពីឆ្នាំមុននោះឡើយ ដែលនេះបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩។

ដោយឡែក ចំពោះប្រាក់បញ្ញើវិញ ឃើញថានៅតែបន្តមានកំណើនខ្លាំង ដោយសារតែវិនិយោគិន(អតិថិជន) បានដាក់ប្រាក់បញ្ញើ ខណៈពុំទាន់រកឃើញឱកាសអាជីវកម្មថ្មីក្នុងកំឡុងពេលមានវិបត្តិនេះ។

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ VietnamPlus ចេញផ្សាយ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១*

## ធនាគារពិភពលោក បានប្តេជ្ញាជួយជំរុញសេដ្ឋកិច្ចកម្ពុជា ទោះបីកំពុងស្ថិតក្នុងអំឡុងការរីករាលដាលជំងឺកូវីដ ១៩



*រូបថត AFP*

លោក David Malpass ប្រធានធនាគារពិភពលោក បានលើកឡើងថា ការរីករាលដាលជំងឺកូវីដ ១៩ បានធ្វើឱ្យប្រាក់ចំណូលរបស់រដ្ឋាភិបាលនៃប្រទេសទូទាំងពិភពលោកធ្លាក់ចុះ។

លោកបានបន្តថា កម្ពុជាស្ថិតនៅក្នុងចំណោមបណ្តាប្រទេសជាច្រើនផ្សេងទៀត នៅតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក ដែលទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីធនាគារពិភពលោក សម្រាប់ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ច។ នេះជាកិច្ចខិតខំប្រឹងប្រែងមួយដោយធនាគារពិភពលោក ក្នុងការផ្តល់ការគាំទ្រដល់ប្រទេស

ទាំងឡាយរួមទាំងកម្ពុជា។ កន្លងមក ធនាគារពិភពលោក បានផ្តល់ប្រាក់ ១,១ ប៊ីលានដុល្លារដល់បណ្តាប្រទេសជាច្រើននៅអាស៊ីខាងកើត និងប៉ាស៊ីហ្វិករួចហើយ ដែលរួមមានប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ុងហ្គោលី ឡាវ ប៉ាពូអាស៊ីនូវែលហ្គីណេ និងហ្វីលីពីន ហើយក៏មានបំណងផ្តល់បន្ថែមទៀតផងដែរ។

លោកស្រី Victoria Kwakwa អនុប្រធានធនាគារពិភពលោក ទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក បាននិយាយដែរថា កម្ពុជានៅពេលនេះបានចាក់វ៉ាក់សាំងដល់ប្រជាជនបានកម្រិតខ្ពស់បំផុតនៅក្នុងតំបន់នេះ ឬអាចខ្ពស់បំផុតទី២ បន្ទាប់ពីប្រទេសសិង្ហបុរី។ ការពន្លឿនការចាក់វ៉ាក់សាំងនេះ ហើយនឹងការកំពុងព្យាយាមធ្វើឱ្យបានកាន់តែច្រើនថែមទៀតគឺជាល្អ ។

លោកស្រីបន្ថែមទៀតថា សេដ្ឋកិច្ចប្រទេសកម្ពុជាអាចកើនឡើងប្រហែល៤% ក្នុងករណីដែលកម្ពុជាអាចទទួលបានជោគជ័យ នៅក្នុងការធ្វើឱ្យវីរុសបំប្លែងថ្មីស្ថិតក្រោមការគ្រប់គ្រង និងត្រឡប់ទៅរកផ្លូវប្រក្រតី នៃការបង្កើនការនាំចេញមួយចំនួន និងជំរុញកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលបានចុះហត្ថលេខា ព្រមជាមួយនឹងការកែទម្រង់ដែលបានរំពឹងទុកមួយចំនួន ទាក់ទងនឹងការវិនិយោគបរទេស។ ក្នុងករណីសេណារីយោមិនល្អ កំណើនសេដ្ឋកិច្ចកម្ពុជានឹងធ្លាក់ចុះក្នុងរង្វង់កំណើនត្រឹម១%ប៉ុណ្ណោះ ប្រសិនបើកម្ពុជាមិនអាចដោះស្រាយបានល្អលើការរីករាលដាលជំងឺកូវីដ ១៩។

លោកស្រីលើកឡើងថា ក្រុមហ៊ុនឯកជនជាច្រើនកំពុងធ្លាក់ចុះដោយសារតែការរីករាលដាលជំងឺកូវីដ ១៩ ហើយសកម្មភាពរបស់ពួកគេមានការជាប់ទាក់ទងនឹងវិស័យធនាគារ ដែលមានភាពងាយទទួលរងហានិភ័យ។ ដូច្នេះ វិស័យទាំងនោះចាំបាច់ត្រូវទទួលការពិនិត្យដោយប្រុងប្រយ័ត្ន ដើម្បីធ្វើឱ្យប្រាកដថានឹងមិនមានកត្តាជំរុញណាមួយដែលបង្កឱ្យមានអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

យោងតាមកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) បានឱ្យដឹងតាមរយៈការសិក្សាមួយថា វិស័យចំនួន៣ រងផលប៉ះពាល់ខ្លាំងបំផុត គឺប្រាក់ចំណូលក្នុងស្រុក ការវិនិយោគផ្ទាល់ពីបរទេស (FDI) និងការវិនិយោគក្នុងស្រុកឯកជន។

អគ្គនាយកដ្ឋានពន្ធដារ ប្រមូលប្រាក់ចំណូលពន្ធនៅឆមាសទី១ ឆ្នាំ២០២១ ធ្លាក់ចុះ១០,៦០%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ រីឯអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានប្រមូលចំណូលនៅក្នុងឆមាសទី១ ឆ្នាំ២០២១ ធ្លាក់ចុះ៨,៩%ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនដែរ។ នេះគឺផលប៉ះពាល់ដ៏ធំដែលចំណូល ដែលជាធាតុមួយសំខាន់សម្រាប់កសាងប្រទេស៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ ភ្នំពេញបុស្តិ៍ ចេញផ្សាយថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២១*

## រាជរដ្ឋាភិបាលកម្ពុជាចំណាយថវិកាចំនួន ៣៨០លានដុល្លារ សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជំនួយសង្គម



*ប្រភព៖khmertimes, 2021*

កម្មវិធីឧបត្ថម្ភជាសាច់ប្រាក់ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានបង្កើតឡើងកាលពីខែមិថុនា ឆ្នាំ២០២០ គឺជាការផ្ទេរសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះដែលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ១៩។ តាមរយៈសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្ហាញថា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជុំទី៥ ត្រូវបានបញ្ចប់ហើយ ដែលក្នុងនោះ រាជរដ្ឋាភិបាលបានចំណាយថវិកាប្រមាណ ៣៨១លានដុល្លារ សម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដើម្បីជួយប្រជាពលរដ្ឋ ដែលរងការប៉ះពាល់ធ្ងន់ធ្ងរដោយវិបត្តិជំងឺកូវីដ១៩។

សូមបញ្ជាក់ផងដែរ ក្នុងចំណោមប្រជាជន ២,៦លាននាក់ មានគ្រួសារប្រមាណ ៦៥៨ ៨៥៧គ្រួសារ បានទទួលអត្ថប្រយោជន៍ពីកម្មវិធីនេះ។ បច្ចុប្បន្ននេះ ៩៥% នៃគ្រួសារក្រីក្រ ដែលមានប័ណ្ណបញ្ជាក់ពីភាពក្រីក្រគឺស្ថិតនៅតាមទីជនបទ ខណៈដែលគ្រួសារក្រីក្រមួយចំនួនតូចស្ថិតនៅតំបន់ទីប្រជុំជន។

ស្របពេលដែលកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជុំទី៥ ត្រូវបានបញ្ចប់ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជុំទី៦នឹងត្រូវចាប់ផ្តើមនៅថ្ងៃទី២៥ ខែកក្កដានេះ។ រាល់ក្រុមគ្រួសារនីមួយៗទទួលបានថវិកាចំនួន៣០ដុល្លារក្នុងមួយខែ រួមបញ្ចូលទាំង១០ដុល្លារបន្ថែមសម្រាប់ សមាជិកគ្រួសារម្នាក់ និង ១០ដុល្លារផ្សេងទៀតសម្រាប់ក្មេងនៅក្រោមអាយុ៥ឆ្នាំ ជនពិការ ជនចាស់ជរា និងអ្នកដែលមានផ្ទុកមេរោគអេដស៍។ ប្រជាពលរដ្ឋដែលមានប័ណ្ណក្រីក្រត្រឹមត្រូវ មានសិទ្ធទទួលបានសាច់ប្រាក់ដែលត្រូវបានផ្ទេរឱ្យតាមរយៈធនាគារឯកទេសវីង នៅទូទាំងប្រទេស៕ *ដោយ សេន ចន្ទ* *ប្រភព៖khmertimeskh. ចេញផ្សាយថ្ងៃទី២៧ខែកក្កដាឆ្នាំ២០២១*

## កសិករដំណាំបន្លែគ្រប់មុខខេត្តរតនគិរី រីករាយដែលលក់បានតម្លៃខ្ពស់ក្នុងឆ្នាំនេះ



*អត្ថបទ៖ ប៉េស សារី ប្រភព៖ CNC, 2021*

អ៊ំស្រី រី សុផល ជាកសិករនៅភូមិប៉ាតាងតា ឃុំប៉ាតាង ស្រុកលំផាត់ ខេត្តរតនគិរី ដែលប្រកបរបរដាំបន្លែគ្រប់មុខជិត១០ឆ្នាំមកហើយនោះ កំពុងតែសប្បាយចិត្តក្នុងការលក់បន្លែបានថ្លៃខ្ពស់ជាងឆ្នាំមុន។ ឆ្នាំនេះបន្លែដែលមានទីផ្សារខ្លាំងជាងគេគឺ បន្លែសណ្តែកកួរ និងបន្លែស្ពៃ។ បច្ចុប្បន្ន គាត់កំពុងជួលដីគេថែមទៀត ដើម្បីដាំបន្លែវិលជុំសម្រាប់លក់។ ក្រៅពីដាំបន្លែ គាត់មានចិញ្ចឹមមាន់ទា ដាំដំណាំហូបផ្លែ និងចិញ្ចឹមគោជិត២០ក្បាល សម្រាប់យកលាមកគោធ្វើជីដាក់ដំណាំ និងធ្វើស្រែវស្សាសម្រាប់ផ្គត់ផ្គង់ជីវភាពបន្ថែមទៀត។

ជាមួយគ្នានោះដែរ លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី ក៏បានឱ្យដឹងថា សម្រាប់ខេត្តរតនគិរី ចំពោះបណ្តុំអាជីវកម្មបន្លែធម្មជាតិ គឺតែងមានមន្ត្រី ចុះប្រឹក្សាយោបល់ជាមួយប្រជាពលរដ្ឋតាមមូលដ្ឋាន និងស្វែងរកទីផ្សារជួយពួកគាត់។ ក្នុងឆ្នាំ២០២១ មន្ទីរមានការចងក្រងបណ្តុំអាជីវកម្មដំណាំគ្រួសារចំនួន២៩០គ្រួសារ ហើយផ្តល់ផ្ទះសំណាញ់មួយចំនួនសម្រាប់កសិករ។ កាលពីឆ្នាំ២០២០ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់ផ្ទះសំណាញ់

មួយចំនួនដល់កសិករដាំបន្លែ ចំនួន ២០៤គ្រួសារ។ លោកបន្តថា បច្ចុប្បន្ន កសិករដែលដាំបន្លែគ្រប់មុខទូទាំងខេត្ត មានចំនួន៦៩០គ្រួសារ ហើយពេលនេះពួកគាត់កំពុងសប្បាយចិត្ត ក្នុងការប្រមូលផល និងលក់បានតម្លៃខ្ពស់៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ CNC នាថ្ងៃទី ចេញផ្សាយ២៣-កក្កដា-២០២១*

## កសិករស្រុកឈូកខេត្តកំពត ដាំស្លឹកគ្រៃប្រេងសម្រាប់នាំចេញទៅកាន់ប្រទេសចិន និងបារាំង



*វិឡុជាតិកម្ពុជា៖ ម៉ៅ សុខមី ប្រភព៖ ក្រសួងព័ត៌មាន, 2021*

កសិករស្រុកឈូក ខេត្តកំពត ដាំស្លឹកគ្រៃប្រេង Yava សម្រាប់នាំចេញទៅកាន់ប្រទេសចិន និងបារាំង ដោយសារមានតម្រូវការទីផ្សារនាំចេញខ្លាំង ។ ស្លឹកគ្រៃប្រេង Yava នេះ ជាប្រភេទដំណាំកសិឧស្សាហកម្មបែបទំនើប ត្រូវបានប្រជាសហគមន៍នាំយកពូជមកពីប្រទេសម៉ាឡេស៊ី។ វាជាប្រភេទដំណាំងាយស្រួលដាំ និងឆាប់ប្រមូលផលបាន។

គល់ស្លឹកគ្រៃប្រេងនេះ មានអត្ថប្រយោជន៍ជាច្រើន គឺយើងអាចចម្រាញ់យកប្រេងដើម្បីធ្វើជាឱសថ ទឹកអប់ សាប៊ូកក់សក់ និងគ្រឿងទេសជាច្រើនប្រភេទទៀត។

ដំណាំស្លឹកគ្រៃប្រេងនេះ បើដាំលើផ្ទៃដី១ហិកតា គេត្រូវប្រើពូជប្រមាណ ១តោន ហើយអាចប្រមូលផលវិញបាន ចាប់ពី៨០ទៅ១២០តោនក្នុងមួយឆ្នាំ។ សម្រាប់ស្លឹកគ្រៃប្រេងYava នេះ សហគមន៍លក់ចេញជា០២ផ្នែក គឺ ស្លឹកចំនួន១តោនមានតម្លៃ ៥០ដុល្លារ ហើយបើចម្រាញ់ជាប្រេងរួច គឺលក់បានចំនួន ៨ដុល្លារសហរដ្ឋអាមេរិកក្នុងមួយលីត្រ។

លោកអ៊ុ វត្ថខេមរា សហការីកសិដ្ឋាន ខេស៊ី ស្ថិតក្នុងភូមិដុំផ្ដៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពតបានលើកឡើងថា ប្រជាកសិករនៅក្នុងប្រទេសកម្ពុជា សូមនាំគ្នាផ្លាស់ប្ដូរផ្នត់គំនិតពីការដាំដំណាំ តាមបែបគ្រួសារមកដាំតាមបែបសហគមន៍វិញ ទើបអាចមានទីផ្សារនាំចេញទៅក្រៅប្រទេសបាន។ ការដាំ តាមគ្រួសាររបៀបដូនតា ពិបាករកទីផ្សារ តែប្រសិនបើគាត់ដាំតាមបែបសហគមន៍ នោះអាចមានទីផ្សារ ដូច្នេះ គួរតែផ្លាស់ប្ដូរមកដាំតាមសហគមន៍វិញ ទើបគាត់មានភាពរីកចម្រើន។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ក្រសួងព័ត៌មាន ចេញផ្សាយ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០២១*

# តារាងប្រចាំសប្ដាហ៍

## តារាងទី១៖ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសប្រចាំខែឧសភានៅឆ្នាំ២០២១

| បរិយាយ(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា |
|---|---|---|---|---|---|
| ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 159.5 | 153.1 | 238.5 | 106.6 | 188.72 |
| កំណើន(%) | | -4.0% | 55.8% | -55.3% | 77.1% |
| ពន្ធ និងអាករលើការនាំចូល | 156.89 | 150.79 | 233.60 | 103.46 | 184.97 |
| កំណើន(%) | | -3.9% | 54.9% | -55.7% | 78.8% |
| ពន្ធ និងអាករលើការនាំចេញ | 2.64 | 2.35 | 4.92 | 3.12 | 3.75 |
| កំណើន(%) | | -11.0% | 109.4% | -36.6% | 20.2% |

*ប្រភព៖ តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែឧសភាឆ្នាំ២០២១នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ នៅក្នុងខែឧសភាឆ្នាំ២០២១នេះ រដ្ឋបាលថ្នាក់ជាតិ បានប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស មានចំនួនសរុប ១៨៨,៧២ប៊ីលានរៀល ដែលមានកំណើនយ៉ាងខ្លាំងប្រមាណជា ៧៧,១% បើធៀបនឹងខែមេសា នៃឆ្នាំដដែល។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូល បានប្រមាណជា ១៨៤,៩៧ប៊ីលានរៀល នៅក្នុងខែឧសភាឆ្នាំ២០២១នេះ ដែលមានការកើនយ៉ាងខ្លាំងរហូតដល់ ៧៨,៨% បើធៀបនឹងខែមេសា។

ស្របពេលនោះដែរ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញ មានចំនួន ៣,៧៥ប៊ីលានរៀលនៅក្នុងខែឧសភា ឆ្នាំ២០២១ ដែលមានការកើនឡើងប្រមាណជា ២០,២% បើធៀបនឹងខែមេសា។*ដោយ៖ មិត្ត ចន្ធី*

## តារាងទី២៖ ពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិក លើមុខទំនិញនៅក្នុងខែឧសភាឆ្នាំ២០២០១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា៖ នៅក្នុងខែឧសភា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់ប្រមាណជា ៦៥០,៣លានដុល្លារ ដែលមានការធ្លាក់ចុះបន្តិចប្រមាណជា ៥,២% បើធៀបនឹងខែមេសា ឆ្នាំ២០២១។

ជាក់ស្តែង នៅក្នុងខែឧសភា ឆ្នាំ២០២១ ការនាំចេញទំនិញរបស់កម្ពុជាទៅសហរដ្ឋអាមេរិក មានទំហំទឹកប្រាក់ប្រមាណ ជា ៦១២,២លានដុល្លារ ដែលមានការធ្លាក់ចុះប្រហែល ៦,៧% បើធៀបនឹងខែមេសា។ ការនាំចេញនេះ ភាគច្រើនជាប្រភេទទំនិញសម្រាប់ធ្វើដំណើរដូចជា៖ ការបូបយួរ ការបូបដាក់លុយ និងគ្រឿងអលង្ការ ទំនិញសំលៀកបំពាក់ ស្បែកជើង និងផលិតផលផ្សេងៗទៀត។

ផ្ទុយទៅវិញ ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិក មកកម្ពុជា មានទំហំទឹកប្រាក់ ៣៨,១លានដុល្លារនៅក្នុងខែឧសភា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ២៩,៦% បើធៀបនឹងខែមេសា។ ការនាំចូលទំនិញសំខាន់ៗទាំងនេះរួមមាន៖ រថយន្តធ្វើដំណើរ គ្រឿងបន្លាស់យានយន្ត ផលិតផលស្បែកសត្វ (raw furskin) និងផលិតផលផ្សេងៗទៀត។*ដោយ មិត្ត ចន្ធី*

| **បរិយាយ** | មករា | កុម្ភៈ | មីនា | មេសា | ឧសភា |
|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **614.5** | **572.7** | **782.1** | **685.7** | **650.3** |
| កំណើន % | | -6.8% | 36.6% | -12.3% | -5.2% |
| នាំចូល | 33.9 | 33.3 | 39.1 | 29.4 | 38.1 |
| កំណើន % | | -1.8% | 17.4% | -24.8% | 29.6% |
| នាំចេញ | 580.6 | 539.4 | 743.0 | 656.3 | 612.2 |
| កំណើន % | | -7.1% | 37.7% | -11.7% | -6.7% |

*ប្រភព៖ការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យពាណិជ្ជកម្មសហរដ្ឋអាមេរិក* (**គិតជាលានដុល្លារ**)

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ស្ថានភាពការអនុវត្តថវិកានៃប្រទេសកម្ពុជា ថៃ ហ្វីលីពីន និងវៀតណាម ក្នុងរយៈពេល ៥ខែដំបូង ឆ្នាំ២០២១




*ប្រភព៖ ក្រសួងហិរញ្ញវត្ថុ និងទីភ្នាក់ងារស្ថិតិ នៃប្រទេសនីមួយៗ(ទិន្នន័យបឋម)*
*សម្គាល់៖ %នៃកំណើន ធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០*

ក្នុងរយៈពេល៥ខែដំបូងនៃឆ្នាំ២០២១ ការអនុវត្តចំណូលថវិកាសរុបនៃប្រទេសកម្ពុជា ថៃ ហ្វីលីពីន និងវៀតណាម បង្ហាញឱ្យឃើញថា ប្រទេសចំនួន ០៣ខាងលើ (លើកលែងប្រទេសកម្ពុជា) នៅតែមានលទ្ធភាព ក្នុងការកៀរគរចំណូលបានខ្ពស់ជាង រយៈពេលដូចគ្នា ក្នុងឆ្នាំ២០២០ ទោះបីកំពុងស្ថិតក្នុងវិបត្តិជំងឺកូវីដ-១៩ក៏ដោយ។ គួរកត់សម្គាល់ផងដែរ ថ្វីបើប្រទេសកម្ពុជាប្រមូលចំណូលតិចជាងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ ក៏ប៉ុន្តែ បើធៀបនឹងផែនការប្រមូលចំណូលឆ្នាំ២០២១វិញ (ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង) ឃើញថាសម្រេចបានដល់ទៅ ៤៥,៩% ដែលខ្ពស់ជាងការអនុវត្តនៅឆ្នាំ២០២០ ដែលសម្រេចបានត្រឹមតែ ៤០,២%នៃផែនការ។

ដោយឡែក ចំពោះ ចំណាយថវិកាជាតិវិញ ឃើញថា ក្នុងចំណោមប្រទេសទាំង០៤ខាងលើនេះ មានតែប្រទេសហ្វីលីពីនប៉ុណ្ណោះ ដែលចំណាយថវិកាសរុបមានការកើនឡើង ប្រមាណជិត ៩% (ពីមករា ដល់ខែឧសភា) ដែលខ្ពស់ជាងរយៈពេលដូចគ្នា នៅឆ្នាំ២០២០ ខណៈដែល ការអនុវត្តថវិកាចំណាយនៃប្រទេសកម្ពុជា ថៃ និងវៀតណាម គឺទាបជាងការអនុវត្តក្នុងរយៈពេលដូចគ្នា នៅឆ្នាំ២០២០។ ជាសរុប ឱនភាពថវិកាសរុបនៃប្រទេសហ្វីលីពីន មានការកើនឡើង ក្នុងរយៈពេល ០៥ ខែដំបូងនៃឆ្នាំនេះ បើធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំមុន។ ខណៈដែល ឱនភាពថវិកាក្នុងប្រទេស ០៣ ទៀត សុទ្ធតែទាបជាង លទ្ធផលអនុវត្តកាលពីឆ្នាំ ២០២០កន្លងទៅ។ ដោយ***ជា សិរីរតន៍***

*ប្រភព៖ ក្រសួងហិរញ្ញវត្ថុ និងទីភ្នាក់ងារស្ថិតិ នៃប្រទេសនីមួយៗ (ទិន្នន័យបឋម)*

### ក្រសួងហិរញ្ញវត្ថុវៀតណាមកំពុងធ្វើការលើកញ្ចប់ថវិកាជំនួយ ចំនួន ១,០៤ ប៊ីលានដុល្លារអាមេរិក



*ប្រភព៖ Viet Name News , រូបភាព៖ kinhtemoitruong.vn*

ក្រសួងហិរញ្ញវត្ថុវៀតណាម (Ministry of Finance) កំពុងរៀបចំសំណើកញ្ចប់ថវិកាគាំទ្រ VND២៤ ទ្រីលានដុង (ស្មើនឹង១,០៤ប៊ីលានដុល្លារអាមេរិក) ដើម្បីជួយអាជីវកម្មដែលរងផលប៉ះពាល់ដោយការឆ្លងរាតត្បាត

នៃជំងឺកូវីដ១៩ តាមរយៈការលើកលែងពន្ធ និងការកាត់បន្ថយពន្ធ រួមទាំងថ្លៃសេវា។

រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ លោក (Hồ Đức Phớc) បានលើកឡើងនៅក្នុងកិច្ចពិភាក្សាស្តីអំពីការអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងផែនការថវិការបស់រដ្ឋសម្រាប់រយៈពេល៦ខែដំបូងឆ្នាំនេះ ហើយសំណើកញ្ចប់ថវិកាខាងលើនេះនឹងត្រូវបញ្ជូនទៅរដ្ឋសភា និងរដ្ឋាភិបាលដើម្បីធ្វើការអនុម័ត។ បន្ថែមពីនេះ ក្រសួងក៏បានរៀបចំសំណើសុំពន្យាពេលនៃការអនុវត្តសារាចរលេខ ៤០/TT-BTC ស្តីពីពន្ធអាជីវកម្មគ្រួសារ រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២២ ដើម្បីជួយសម្រួលដល់អ្នកជាប់ពន្ធ។

កាលពីពេលថ្មីៗនេះ រដ្ឋាភិបាលបានអនុម័តលើផែនការគាំទ្រចំនួនVNĐ២៦ទ្រីលានដុង សម្រាប់អាជីវកម្ម និងបុគ្គល ដែលរងផលប៉ះពាល់ដោយជំងឺកូវីដ១៩ ដែលបច្ចុប្បន្ននេះកញ្ចប់ជំនួយកំពុងត្រូវបានផ្តល់ឱ្យដល់អាជីវកម្មជាបន្តបន្ទាប់។

ដោយឡែក សម្រាប់ក្រសួងសុខាភិបាលវិញ ក្រសួងហិរញ្ញវត្ថុបានផ្តល់ថវិកាជិត VNĐ៨,២ទ្រីលានដុង ដើម្បីចំណាយលើវ៉ាក់សាំង និងVNĐ១២,៣ទ្រីលានដុង សម្រាប់ដំណើរការផ្សេងទៀត។

ដើម្បីទទួលបានធនធានបន្ថែមសម្រាប់ការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ក្រសួងស្នើសុំរដ្ឋាភិបាលកាត់បន្ថយចំណាយជាប្រចាំចំនួន ១០% និងកម្រៃសម្រាប់ការប្រជុំ និងថ្លៃធុរកិច្ចចំនួន ៥០%។ ទន្ទឹមនឹងនេះរដ្ឋាភិបាលត្រូវការបង្កើននូវប្រសិទ្ធភាពនៃការវិនិយោគសាធារណៈរួមទាំងគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការ និងកាត់គម្រោងដែលគ្មានប្រសិទ្ធភាពជាមួយនឹងការគ្រប់គ្រងមូលប័ត្រជានាប៉ាប់រង និងទីផ្សាររូបិយប័ណ្ណ។ ចំណែកឯគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុគួរតែត្រូវបានសម្របសម្រួលឱ្យមានភាពល្អប្រសើរផងដែរ។

នៅក្នុងឆមាសទីមួយឆ្នាំ២០២១ ស្ថានភាពសេដ្ឋកិច្ច-សង្គមមានភាពវិជ្ជមានជាមួយនឹងកំណើនផលិតផលក្នុងស្រុកសរុបស្មើនឹង ៥,៦៤ % ហើយការប្រមូលថវិការដ្ឋបានឈានដល់ ៥៨,២%នៃផែនការ ពោលគឺកើនឡើង ១៦,៣ %ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការចំណាយថវិការដ្ឋធានាបាននូវប្រសិទ្ធភាព ដោយអនុវត្តបាន ៤១,២ %នៃផែនការ។

បំណុលសាធារណៈក៏មាននិរន្តរភាពសម្រាប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញដែរ។ មូលបត្របំណុលរដ្ឋាភិបាលត្រូវបានបោះចេញដែលមានរយៈពេលរហូតដល់ ១២ ឆ្នាំដោយមានអត្រាការប្រាក់ត្រឹមតែ ២,៦%ទៅ២,៧ % ក្នុងមួយឆ្នាំ។

ទីផ្សារការធានារ៉ាប់រង និងទីផ្សាររូបិយវត្ថុមានការរីកចម្រើនល្អដែលរួមមានទាំងមូលប័ត្រភាគហ៊ុន ប័ណ្ណភាគហ៊ុន និងទីផ្សារហិរញ្ញវត្ថុ។ ទីផ្សារការធានារ៉ាប់រងបានកើនឡើង ១៦,២ %។ *ដោយ មុំ ចិន្តា*

*ប្រភព៖ Viet Name News ចេញផ្សាយថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០២១*

## វិស័យទេសចរណ៍ថៃឈានដល់កម្រិតទាបបំផុត នៅក្នុងឆ្នាំ ២០២១


*ប្រភព៖* [Bangkok Post ២០២១ Wichan Charoenkiatpakul]

យោងតាមអាជ្ញាធរទេសចរណ៍ថៃ(Tourism Authority of Thainland, TAT)បានឱ្យដឹងថា វិស័យទេសចរណ៍ប្រទេសថៃនៅក្នុងឆ្នាំនេះធ្លាក់ចុះកម្រិតទាបបំផុត ដោយភ្ញៀវទេសចរអន្តរជាតិអាចនឹងមានចំនួនត្រឹមតែ ១ លាននាក់ ខណៈដែលទេសចរណ៍ក្នុងស្រុកអាចធ្លាក់ចុះរហូតដល់ ៥០ទៅ៦០ លាននាក់ ប្រសិនបើស្ថានភាពកាន់តែអាក្រក់នៃជំងឺកូវីដ១៩ ដែលតម្រូវឱ្យមានការបិទខ្ទប់ប្រទេសរហូតដល់បីខែ។

ទោះបីជាការបើកឡើងវិញ សម្រាប់ភ្ញៀវទេសចរអន្តរជាតិដែលបានចាក់វ៉ាក់សាំងរួច តាមរយៈគម្រោងទេសចរភូគេត និងសាមុយ (Phuket sandbox scheme and Samui Plus Model) ក៏ប្រទេសថៃអាចទទួលបានទេសចរអន្តរជាតិត្រឹមតែ ១ លាននាក់ក្នុងឆ្នាំនេះ គឺធ្លាក់ចុះ ៨២% បើប្រៀបធៀបទៅនឹងឆ្នាំកន្លងទៅ ដែលមានចំនួន ៦,៧ លាននាក់។ ចំណែកឯ ប្រាក់ចំណូលពីភ្ញៀវទេសចរអន្តរជាតិ អាចនឹងមានចំនួន ៨៥ប៊ីលានបាត ធ្លាក់ចុះ ៧៤%ធៀបនឹងឆ្នាំ២០២០។

ដោយសារតែការផ្ទុះឡើងយ៉ាងខ្លាំងនៃជំងឺកូវីដ១៩ បានជំរុញឱ្យមានការរាំងស្ទះ និងការរឹតត្បិតក្នុងការធ្វើដំណើរ ក្នុងទិសដៅសំខាន់ៗជាច្រើនរួមទាំងចំណុចកណ្ដាលនៃទីក្រុងបាងកក ដែលប្រទេសថៃ ត្រូវការរយៈពេលបីខែដើម្បីទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងនេះ។

ប្រសិនបើប្រទេសថៃត្រូវការពេលវេលាលើសពីបីខែដើម្បីគ្រប់គ្រងស្ថានការណ៍នេះ ចំនួននៃការធ្វើដំណើរក្នុងស្រុកអាចនឹងថយចុះរហូតដល់៥០ ទៅ៦០លាននាក់ ។

យោងតាមការព្យាករណ៍របស់ TAT ប្រាក់ចំណូលទេសចរណ៍សរុបក្នុងឆ្នាំ ២០២១ អាចនឹងធ្លាក់ចុះ ២៣% ស្មើនឹង ៦២៥ ប៊ីលានបាតក្នុងនោះមាន ១៤% ពីទីផ្សារអន្តរជាតិ និង ៨៦% ពីទេសចរណ៍ក្នុងស្រុក។

ទន្ទឹមនឹងនេះគោលដៅអប្បបរមាសម្រាប់ទីផ្សារទេសចរអន្តរជាតិនៅឆ្នាំ ២០២២ ត្រូវបានកំណត់ចំនួន ១០ លាននាក់ ខណៈដែលទេសចរណ៍ក្នុងស្រុកត្រូវបានគេរំពឹងថានឹងមានការធ្វើដំណើរចំនួន ១២២ លាននាក់។ សម្រាប់ប្រាក់ចំណូលសរុបវិញត្រូវបានរំពឹងថាមានចំនួន ១ ៣០៥ប៊ីលានបាត ក្នុងនោះទេសចរអន្តរជាតិមានចំនួន ៦២៥ប៊ីលានបាត និងទេសចរណ៍ក្នុងស្រុកចំនួន ៦៨០ប៊ីលានបាត៕ *ដោយ មុំ ចិន្តា*

*ប្រភព៖* [Bangkok Post ចេញផ្សាយថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០២១]

## ទីក្រុងភាគកណ្តាល វៀតណាម ទាក់ទាញការវិនិយោគ នៅអំឡុងពេលការវាយប្រហាយដោយកូវីដ១៩



*រូបថត Trung Nam Group*

វិនិយោគបរទេស ដែលមានសក្តានុពលកំពុងតែសំឡឹងមើលការបង្កើតរោងចក្រនៅភូមិភាគកណ្តាលនៃប្រទេសវៀតណាម បើទោះបីជាមានការរីករាលដាលនៃកូវីដ១៩ ក៏ដោយ។

លោក Pham Truong Son ប្រធាននៃអាជ្ញាធរសួន Da Nang Hi-tech និងសួនឧស្សាហកម្មនៃភូមិភាគកណ្តាលនេះ បាននិយាយថា រោងចក្រផលិតគ្រឿងបន្លាស់ Vector Fabrication Inc របស់សហរដ្ឋអាមេរិក កំពុងស្វែងរកទីតាំងសម្រាប់ផលិតកម្មប្រព័ន្ធរោងចក្រអេឡិច-ត្រូនិកខ្នាតតូច ក្នុងដើមទុនប្រមាណ ៦០ លានដុល្លារអាមេរិក។ លោកបានបន្តថា នេះជាសញ្ញាវិជ្ជមាននៃការវិនិយោគបរទេសក្នុងកំឡុងពេលមានជំងឺរាតត្បាតកូវីដ១៩ ដែលបានរាតត្បាតដល់ទីក្រុង និងខេត្តជាច្រើននៅវៀតណាម។

សរុបមក ទឹកប្រាក់សរុបចំនួន ១៤៥,៣ លានដុល្លារអាមេរិក ពីគម្រោងវិនិយោគផ្ទាល់ពីបរទេសចំនួន ១៦ និងទឹកប្រាក់ចំនួន ៤៨១ ពាន់លានដុង (២១ លានដុល្លារ) ពីគម្រោងក្នុងស្រុកចំនួន ១២ ដែលបានបោះទុនក្នុងរយៈពេល ៦ ខែដំបូងនៃឆ្នាំនេះ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយនាថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២១*

# សេដ្ឋកិច្ចសកល

## អាមេរិកកំណត់គោលដៅជំរុញកំណើនសេដ្ឋកិច្ចសកល ស្របបរិបទនៃការងើបឡើងវិញរបស់សេដ្ឋកិច្ច




*រូបថតដោយ៖ MARCIO JOSE SANCHEZ/ASSOCIATED PRESS*

នៅក្នុងអំឡុងបីខែចុងក្រោយ គិតត្រឹមខែមិថុនានេះ សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកទំនងជាវិលត្រលប់ទៅរកស្ថានភាពដើមដូចចុងឆ្នាំ២០១៩វិញ និងបានជួយជំរុញឱ្យសេដ្ឋកិច្ចរបស់សាកលលោកមានកំណើនល្អប្រសើរជាងមុនពេលមានវិបត្តិកូវីដ១៩។ នេះគឺជាលើកទីមួយហើយដែលសេដ្ឋកិច្ចពិភពលោក មានសញ្ញាណវិជ្ជមានបន្ទាប់ពីវងគ្រោះដោយសារកូវីដ១៩។ យោងតាមការព្យាករណ៍របស់សេដ្ឋវិទូរ តួលេខដែលនឹងត្រូវចេញផ្សាយនៅថ្ងៃព្រហស្បិ៍សប្តាហ៍នេះ នឹងបង្ហាញថា ផ.ស .ស របស់សហរដ្ឋអាមេរិកនៅក្នុងត្រីមាសទីពីរមានកំណើន ៨,៥% (ផ.ស.ស ជាតម្លៃទំនិញ និងសេវាទាំងអស់ក្នុងសេដ្ឋកិច្ច) ដែលកើនឡើងលើសត្រីមាសទី៤ ឆ្នាំ២០១៩ ដែលមានកម្រិត ១៩,២ទ្រីលានដុល្លារ។

បន្ថែមពីនោះបើយោងតាមការព្យាករ៍របស់ OECD (អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច)

សេដ្ឋកិច្ចសរុបរបស់ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿនទាំង២០ បានកើនឡើងលើសមុនពេលមានវិបត្តិកូវីដ១៩ នៅត្រីមាសទី១ ឆ្នាំ២០២១។ ដូចនេះ ប្រសិនបើយោងទៅលើកំណើនសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក រួមជាមួយកំណើនសេដ្ឋកិច្ចរបស់ប្រទេស ដែលមានសេដ្ឋកិច្ចជឿនលឿនមួយចំនួនទៀតក្នុងត្រីមាសទី២នេះ ឃើញថា សេដ្ឋកិច្ចពិភពលោកនៅក្នុងពេលបច្ចុប្បន្ន ទំនងជាមានកំណើនខ្ពស់ជាងមុនពេលមានវិបត្តិកូវីដ១៩។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍អឺរ៉ុបបានកត់សម្គាល់ថា សេដ្ឋកិច្ចអឺរ៉ុបទំនងនៅតែមានកំណើនទាបជាងមុនពេលមានវិបត្តិកូវីដ១៩ ខណៈដែលកូវីដបំប្លែងខ្លួនថ្មីឈ្មោះថា Delta កំពុងតែរីកសាយភាយខ្លាំងនៅតំបន់អាស៊ី។ ទន្ទឹមនឹងនេះ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានធ្វើការព្យាករណ៍ កំណើនសេដ្ឋកិច្ចពិភពលោកជាថ្មីម្តងទៀតក្នុងខែកក្កដា និងបានបង្ហាញថា ក្នុងឆ្នាំ២០២១ កំណើនសេដ្ឋកិច្ចពិភពលោកនឹងរក្សាបានកំណើន ៦% ដូចការព្យាករណ៍ដែលបានធ្វើឡើងកាលពីខែមេសាកន្លងទៅ។ ប៉ុន្តែសេដ្ឋកិច្ចរបស់ប្រទេសធំៗ ដែលជាប្រទេសអ្នកមានហាក់មានកំណើនល្អប្រសើរជាងមុន ដោយសារកំណើននៃការចាក់វ៉ាក់សាំងនៅបណ្តាប្រទេសទាំងនោះមានសន្ទុះខ្លាំង ខណៈដែលសេដ្ឋកិច្ចប្រទេសក្រីក្រ នៅតែមានភាពទន់ខ្សោយ។ ជារួម យោងតាមការព្យាករណ៍របស់ IMF ទោះបីជាការព្យាករណ៍នៅក្នុងខែកក្កដា ធៀបទៅនឹងខែមេសាបង្ហាញថា កំណើនសេដ្ឋកិច្ចសាកលលោករក្សាបានកំណើនក្នុងអត្រា ៦% ដដែលក្តី ប៉ុន្តែសមាសធាតុនៅក្នុងការព្យាករណ៍មានការប្រែប្រួលគួរឱ្យកត់សម្គាល់។

ឧទាហរណ៍៖ នៅសហរដ្ឋអាមេរិក អាជីវកម្មផ្សេងៗបានកំពុងបើកឱ្យមានដំណើរការឡើងវិញជាបន្តបន្ទាប់ ខណៈការចាក់វ៉ាក់សាំងមានការកើនឡើង។ ទន្ទឹមនឹងនេះ រដ្ឋាភិបាលបានបង្កើនកញ្ចប់ជំនួយដ៏ធំសម្បើម ដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ កត្តានេះបានបង្ហាញថា ផ.ស.ស របស់សហរដ្ឋអាមេរិកនៅចុងឆ្នាំ២០២២ ទំនងជានឹងមានកំណើនខ្ពស់ជាងការព្យាករណ៍ ដែលបានធ្វើឡើងមុនពេលមានវិបត្តិកូវីដ១៩។ ម្យ៉ាងវិញទៀត សហរដ្ឋអាមេរិកមិនដែលបិទខ្ទប់ប្រទេសទាំងស្រុង ដូចបណ្តាប្រទេសដទៃទៀតនៅអឺរ៉ុបទេ។ ដោយឡែកសេដ្ឋកិច្ចរបស់សហគមន៍អឺរ៉ុបដែលមានសមាជិកទាំងអស់ ២៧ ប្រទេសអាចនឹងវិលប្រលប់មករកស្ថានភាពដើមវិញនៅត្រីមាសទី៤ ឆ្នាំ២០២១នេះ។ ប៉ុន្តែនៅក្នុងចំណោមនោះ សេដ្ឋកិច្ចរបស់ប្រទេសមួយចំនួននឹងត្រលប់មករកភាពប្រក្រតីវិញលឿន ឬយឺត អាស្រ័យលើទំហំនៃការពឹងផ្អែករបស់ប្រទេសនោះទៅលើវិស័យទេសចរណ៍ និងវិស័យសេវាកម្មផ្សេងទៀត ដែលទទួលរងផលប៉ះពាល់ជាងវិស័យឧស្សាហកម្ម។

សេដ្ឋកិច្ចរបស់ប្រទេសប៉ូឡូញ ទំនងជាបានត្រលប់មកភាពប្រក្រតីវិញក្នុងត្រីមាសទី២។ បន្ទាប់មក សេដ្ឋកិច្ចរបស់ប្រទេសអាឡឺម៉ង់ អាចត្រលប់មករកភាពប្រក្រតីវិញនៅក្នុងត្រីមាសទី៣ ដោយសារការផលិតនៅក្នុងរោងចក្ររបស់ប្រទេសទាំងពីរ ឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការទំនិញនៃទីផ្សារពិភពលោក នៅក្នុងអំឡុងពេលវិបត្តិកូវីដ១៩។ ផ្ទុយទៅវិញ សហគមន៍អឺរ៉ុបរំពឹងទុកថា សេដ្ឋកិច្ចរបស់ប្រទេសអេស្ប៉ាញ និងអ៊ីតាលីអាចនឹងងើបឡើងវិញនៅក្នុងត្រីមាសទី៣ ឆ្នាំ២០២២

ដោយសារតែវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ចនៅក្នុងប្រទេសទាំងពីរនេះមានទំហំធំ និងទទួលរងផលប៉ះពាល់ខ្លាំង។

មូលហេតុមួយទៀតនៃកំណើនយឺត គឺដោយសារតែសន្ទុះនៃការចាក់វ៉ាក់សាំងនៅតាមប្រទេសនីមួយៗមានល្បឿនខុសគ្នា ខណៈដែលការរាតត្បាតកូវីដបំប្លែងថ្មី Delta កំពុងតែគំរាមកំហែងដល់សេដ្ឋកិច្ច។ ឧទាហរណ៍ ឥណ្ឌូដែលជាសមាជិក G-20 មួយដែរនោះ មានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំងនៅក្នុងត្រីមាសទី២ ឆ្នាំ ២០២០ ប៉ុន្តែមានកំណើនខ្ពស់វិញ ក្នុងអត្រា ២,៧% កាលពីត្រីមាសទី១ ឆ្នាំ២០២១ ដែលជាអត្រាខ្ពស់ជាងមុនពេលមានវិបត្តិកូវីដ១៩។ យ៉ាងណាមិញ នៅត្រីមាសទី២ ឆ្នាំ២០២១ ដោយសារប្រជាពលរដ្ឋឥណ្ឌូដែលនៅមិនទាន់បានទទួលវ៉ាក់សាំងមានចំនួនច្រើន មេរោគកូវីដបំប្លែងថ្មីបានវាយលុកឥណ្ឌូយ៉ាងខ្លាំង ធ្វើឱ្យរដ្ឋាភិបាលឥណ្ឌូដាក់ចេញវិធានការបិតខ្ទប់ ដែលបានធ្វើឱ្យវិស័យសេវាកម្ម និងឧស្សាហកម្មនៅឥណ្ឌូធ្លាក់ចុះជាថ្មីទៀត។

ដោយឡែកនៅអាស៊ីវិញ វិធានការបិតខ្ទប់ត្រូវបានដាក់ចេញជាបន្តបន្ទាប់ និងហាក់ដូចជាមានការរឹតបន្តឹងជាងឆ្នាំមុន ដែលនាំឱ្យគេរំពឹងថា សេដ្ឋកិច្ចនៅអាស៊ីអាចនឹងមានការយឺតយ៉ាវក្នុងការត្រលប់មករកភាពប្រក្រតីវិញ៕

*ដោយ វង្ស ច័ន្ទស្មើដាភ*

*ប្រភព៖ គេហទំព័រ The Wall Street Journal ចេញផ្សាយថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២១*

## អាស៊ាន មិនត្រូវបានគ្របដណ្តប់ដោយគោលនយោបាយពន្ធសាជីវកម្មអប្បរមាសកល ដែលអាចកាន់តែមានភាពជិតស្និទ្ធជាមួយចិន




*កាលពីខែមិថុនាក្រុមប្រទេស G-7 បានចុះកិច្ចព្រមព្រៀងយកពន្ធអប្បរមា ១៥% ចំណែកឯរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចទាំង២០ បានគាំទ្រដល់គម្រោងនេះនៅខែកក្កដា។ រូបថតដោយ៖ AP*

របបពន្ធអន្តរជាតិថ្មីត្រូវបានបង្កើតឡើង ដើម្បីជំរុញដល់ការអនុវត្តគោលនយោបាយសារពើពន្ធនៅតាមបណ្តាប្រទេសដែលទទួលរងផលប៉ះពាល់ខ្លាំងដោយសារវិបត្តិកូវីដ១៩។ ពន្ធសាជីវកម្មអប្បបរមាជាសកលត្រូវបានកំណត់យកត្រឹមអត្រា ១៥% និងត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងអន្តរជាតិរវាងរដ្ឋមន្ត្រីហិរញ្ញវត្ថុនៃក្រុមប្រទេសចំនួន ២០ (G20) ដើម្បីរៀបចំឡើងវិញនូវលំហូរវិនិយោគអន្តរជាតិ ដែលបង្កើតឱ្យមានភាពមិនប្រាកដប្រជាដល់ប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលកំពុងតែប្រឹងប្រែង ទាក់ទាញមូលធន និងជំនាញហិរញ្ញវត្ថុពីបរទេស។ គួរបញ្ជាក់ផងដែរថា ប្រទេស G7 ស្នើឱ្យកំណត់ពន្ធសាជីវកម្មអប្បបរមានៅលើពិភពលោកក្នុងអត្រា១៥% ដែលត្រូវបានសម្រេចជ្រើសរើស តាមរយៈការសម្រុះសម្រួលរវាងអត្រាពន្ធ ២១%នៅសហរដ្ឋអាមេរិក

និងអត្រាពន្ធ ១២,៥% ដែលស្នើដោយក្រុមប្រទេសអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច OECD។

បើទោះបីជាការកំណត់ពន្ធអប្បរមានេះ មិនទាន់អនុវត្តភ្លាមៗក្តី ប៉ុន្តែការអនុម័តនូវគោលនយោបាយនេះ អាចបង្ខំឱ្យបណ្តាប្រទេសសមាជិកប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលកំពុងតែមានសេដ្ឋកិច្ចអភិវឌ្ឍន៍លឿន និងកំពុងរងគ្រោះដោយសារវិបត្តិកូវីដ១៩ ត្រូវពឹងផ្អែកខ្លាំងតែលើតម្រូវការទីផ្សារក្នុងស្រុក និងការផ្តត់ផ្គង់កម្លាំងពលកម្មតម្លៃទាប សម្រាប់កំណើនសេដ្ឋកិច្ចរបស់ខ្លួន។ លើសពីនេះ ការកំណត់ពន្ធអប្បរមានេះនឹងអាចនាំឱ្យប៉ះពាល់ដល់គោលនយោបាយការលើកលែងពន្ធនៃបណ្តាប្រទេសអាស៊ី និងទូទាំងពិភពលោក រួមទាំងក្រុមហ៊ុនពហុជាតិ ដែលប្រតិបត្តិការនៅតាមប្រទេសនានា ផ្ទេរទៅប្រទេសដែលយកពន្ធទាប ប៉ុន្តែនៅមានប្រតិបត្តិការផងដែរនៅក្នុងប្រទេសដែលយកពន្ធខ្ពស់។ ម្យ៉ាងទៀត គម្រោងនេះអាចជំរុញឱ្យសមាជិកមួយចំនួននៃអាស៊ាន ពង្រឹងទំនាក់ទំនងជាមួយចិន ដើម្បីពង្រឹងជំហររបស់ពួកគេនៅក្នុងសេដ្ឋកិច្ចពិភពលោក៕ *ដោយ វង្ស ច័ន្ទរស្មីដារា ប្រភព៖ គេហទំព័រ South China Morning Psot ចេញផ្សាយថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០២ ខែសីហា ឆ្នាំ២០២១

- អត្រាអតិផរណាប្រចាំឆ្នាំ របស់ឥណ្ឌូនេស៊ីបានធ្លាក់ចុះ ក្នុងខែមិថុនាឆ្នាំ ២០២១
- សន្ទស្សន៍ទំនុកចិត្តលើផលិតកម្ម នៅក្នុងប្រទេសម៉ិកស៊ិកបានកើនឡើង

ថ្ងៃអង្គារ ទី០៣ ខែសីហា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសប្រេស៊ីល ក្នុងខែមិថុនាឆ្នាំ ២០២១
- អត្រានិកម្មភាព នៅក្នុងប្រទេសអេស្ប៉ាញបានធ្លាក់ចុះ នៅខែមិថុនាឆ្នាំ ២០២១

ថ្ងៃពុធ ខែសីហា ឆ្នាំ២០២១

- អត្រានៃការលក់រាយនៅអូស្ត្រាលីបានធ្លាក់ចុះ ក្នុងខែកក្កដាឆ្នាំ ២០២១
- កំណើនអត្រានៃការលក់រាយ នៅតំបន់ចាយប្រាក់អឺរ៉ូបានកើនឡើង ក្នុងខែឧសភាឆ្នាំ ២០២១

ថ្ងៃព្រហស្បតិ៍ ទី០៥ ខែសីហា ឆ្នាំ២០២១

- ធនាគារកណ្តាលប្រេស៊ីលបានប្រកាសដំឡើងអត្រាការប្រាក់លើកទី៣ នៅឆ្នាំ ២០២១
- ការនាំចេញពីកាណាដា បានថយចុះ នៅត្រឹម ៥ ខែ ត្រឹមខែឧសភា

ថ្ងៃសុក្រ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២១

- កំណើនទុនបម្រុងបរទេសនៅអាហ្វ្រិកខាងត្បូង ក្នុងខែមិថុនាឆ្នាំ ២០២១
- ការងារពេញម៉ោងនៅប្រទេសកាណាដា បានថយចុះ នៅខែមិថុនាឆ្នាំ ២០២១៕